ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Dec-2018, 12:49
CMS/CFO: Sann Rada

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល**

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសាលក្រមនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("បណ្តឹងសាទុក្ខ")[1] ដែលនៅក្នុងនោះ គាត់ស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ធ្វើមោឃភាពសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដោយសារវិការៈនីតិវិធី និងកង្វះសម្អាងហេតុ[2] និងសុំឲ្យប្រកាសទុកជាមោឃៈរាល់ការប៉ុនប៉ងនានាខាងមុខទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់សាលក្រមជាលាយលក្ខណ៍អក្សររបស់ពួកគាត់[3]។ ដូចមូលហេតុថែងខាងក្រោម សហព្រះរាជអាជ្ញាសន្និដ្ឋានថាបណ្តឹងសាទុក្ខនេះមិនអាចទទួលយកបានឡើយនៅក្នុងដំណាក់កាលនេះនៃនីតិវិធី។ ទោះក្នុងករណីណាក៏ដោយ បណ្តឹងសាទុក្ខនេះគ្មានអង្គសេចក្តីសេចក្តីទេ។ គ្មានចំណុចណាមួយនៅក្នុងវិធានផ្ទៃក្នុង ឬទម្លាប់អនុវត្តអន្តរជាតិហាមឃាត់អង្គជំនុំជម្រះមិនឲ្យប្រកាសសេចក្តីសម្រេច ឬសាលក្រមមុនពេលចេញសម្អាងហេតុជាលាយល័ក្ខណ៍អក្សរពេញលេញនោះឡើយ។ ខៀវ សំផន លើកហេតុផលអំពីចរឹកអាក្រក់[4] ក្នុងការប្រកាសសេចក្តីសង្ខេបសាលក្រមនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេលដែលការប្រកាសសាលក្រមជាមុនដូច្នេះ មិនបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីនៃសំណុំរឿង០០២/០២ ណាមួយនោះឡើយ។ ផ្ទុយទៅវិញ ការចេញសេចក្តីសង្ខេបសាលក្រមមុនពេលដែលកាលបរិច្ឆេទសម្រាប់បណ្តឹងសាទុក្ខចាប់ផ្តើមរាប់ គឺជាផលប្រយោជន៍ក្នុងការត្រៀមរៀបចំបណ្តឹងសាទុក្ខដល់ភាគីទាំងអស់ រួមទាំង ខៀវ សំផន ផង។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម ជាភាសាខ្មែរ អង់គ្លេស និងបារាំង ដែលប្រកាសដោយអនុលោមតាមវិធាន

---

[1] ឯកសារ **E463/1** បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ (ដែលបានជូនដំណឹងជាភាសាខ្មែរ និងបារាំង នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ និងជាភាសាអង់គ្លេស នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨) ("បណ្តឹងសាទុក្ខ")។

[2] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ៣-៥, ៥៤-៦៤, ៧០, ៧៣។

[3] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ៣៦-៥៤, ៧៣។

[4] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ, ៥១-៥២។

១០២(១) នៃវិធានផ្ទៃក្នុង[5] ថា "អង្គជំនុំជម្រះនឹងប្រកាសសេចក្តីសង្ខេបសម្អាងហេតុ និងផ្នែកសម្រេចសេចក្តីនៃសាលក្រមក្នុងសំណុំរឿង០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅថ្ងៃសុក្រទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក" និងបានជូនដំណឹងដល់ភាគីថា "សម្អាងហេតុពេលលេញនៃសាលក្រមនេះនឹងត្រូវជូនដំណឹងនៅក្នុងពេលវេលាមួយសមស្រប"[6]។ នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកោះជនជាប់ចោទ នួន ជា និង ខៀវ សំផន ឲ្យចូលខ្លួនដើម្បីស្តាប់សវនាការប្រកាសសាលក្រមនេះ[7]។

3. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងទោសដែលត្រូវដាក់ និងបានផ្តល់សេចក្តីសង្ខេបផ្ទាល់មាត់នៃសាលក្រមនេះ ដោយគូសបញ្ជាក់ពីចំណុចដែលបានរកឃើញសំខាន់ៗ។ អង្គជំនុំជម្រះបានបញ្ជាក់ថា "អង្គជំនុំជម្រះនឹងជម្រាបជូនដល់ភាគី និងសាធារណជនទាំងអស់នៅក្នុងពេលនេះថា អង្គជំនុំជម្រះប្រកាសតែសេចក្តីសង្ខេបនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ។ សម្អាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់ គឺជាសម្អាងហេតុដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរនៅក្នុងសាលក្រម ដែលមានជាភាសាខ្មែរ អង់គ្លេស និងបារាំង ដែលនឹងចេញនៅក្នុងពេលសមស្របខាងមុខ"[8]។

4. សវនាការបានបញ្ចប់ជាមួយនឹងការបញ្ជាក់អះអាងរបស់អង្គជំនុំជម្រះសាលាដំបូងថា "សាលក្រមនេះត្រូវបានប្រកាសនៅក្នុងសាលសវនាការធំ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ ស្របតាមវិធានផ្ទៃក្នុង"[9]។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមថា "ស្របតាមវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ពេលវេលាសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ប្រសិនបើមាន នឹងត្រូវ

---

[5] វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី៩, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង ឬវិធាន")។

[6] ឯកសារ **E462** ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ដែលបានជូនដំណឹងជាភាសាខ្មែរ អង់គ្លេស និងបារាំង នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨) ("ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម"), ទំព័រ២ (អក្សរធំ និងឃ្លាដែលមានគូសបន្ទាត់ពីក្រោមត្រូវបានលុបចេញ)។

[7] ឯកសារ **E202/340** ដីកាកោះជនជាប់ចោទ, ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាកោះ")។

[8] ឯកសារ **E1/529.1** សេចក្តីប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២, ប្រតិចារឹក, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, 09.34.35-09.36.02។

[9] ឯកសារ **E1/529.1** សេចក្តីប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២, ប្រតិចារឹក, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, 11.37.57-11.40.00។

ចាប់ផ្តើមនៅថ្ងៃដំបូងនៃប្រតិទិន បន្ទាប់ពីថ្ងៃជូនដំណឹងនៃសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសម្អាងហេតុពេញលេញជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក តាមការជ្រើសរើសរបស់ភាគីនិមួយៗ អនុលោមតាមមាត្រា ២.២ នៃសេចក្តីណែនាំអនុវត្ត”[10]។

5. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ខៀវ សំផន បានដាក់ពាក្យបណ្តឹងសាទុក្ខរបស់គាត់ជាភាសាខ្មែរ និងបារាំង ដោយបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាបានដាក់សំណើរបស់ខ្លួនដោយស្នើសុំដាក់ចម្លើយតបនេះ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ តែមួយភាសាអង់គ្លេស ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន[11]។

## III. សេចក្តីសន្និដ្ឋាន

### ក. ភាពអាចទទួលយកបាន

6. បណ្តឹងសាទុក្ខនេះ គឺហួសពេល។ ពាក្យបណ្តឹងទាំងមូលរបស់ ខៀវ សំផន គឺថា សេចក្តីសង្ខេបសាលក្រមបានចេញនៅមុនពេលដែលសាលក្រមដែលមានសម្អាងហេតុពេញលេញ ត្រូវបានជូនដំណឹង។ យ៉ាងណាមិញ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ភាគីទាំងអស់ត្រូវបានជូនដំណឹងតាមភាសាទាំងបីរបស់តុលាការ អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រកាសសេចក្តីសង្ខេបសាលក្រមនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយសាលក្រមដែលមានសម្អាងហេតុពេញលេញនឹងចេញតាមក្រោយ[12]។ ខៀវ សំផន អត់ប្តឹងតវ៉ាទៅអង្គជំនុំជម្រះសាលាដំបូង អំពីនីតិវិធីនេះទេ ហើយក៏មិនបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះនៅក្នុងរយៈពេល ៣០ ថ្ងៃកំណត់នោះដែរ[13] (ដែលបានផុតកំណត់នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨)។ រីឯបណ្តឹងសាទុក្ខនៅពេលនេះ បានដាក់នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលជាការហួសពេលហើយ។

---

[10] ឯកសារ **E1/529.1** សេចក្តីប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២, ប្រតិចារឹក, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, 11.37.57-11.40.00។

[11] ឯកសារ **E463/1/1** សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ តែមួយភាសា, ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

[12] ឯកសារ **E462** ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម។

[13] វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

7. ជាការបន្ថែម នៅក្នុងការស្រាវជ្រាវដែលមិនគួរឱ្យជឿជាក់មួយដើម្បីស្វែងរកទ្រឹស្តីអំពីថាតើ ហេតុអ្វីបានជាបណ្តឹងសាទុក្ខនេះអាចទទួលយកបាននៅចំពោះមុខ អ.ជ.ត.ក នៅដំណាក់កាលនេះ ខៀវ សំផន បានផ្តល់ទឡ្ហីករណ៍ផ្សេងចំនួនបីដូចតទៅ៖ (១) វិធាន ១០៤(៤)(ក) និងវិធាន ១០៥(២) (បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេច ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី), (២) វិធាន ១០៥(១)(ខ) (បណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឡើងដោយជនជាប់ចោទ) ឬ (៣) យុត្តាធិការដែលជាប់មកជាមួយរបស់ អ.ជ.ត.ក[14]។ ដូចបានពិភាក្សានៅខាងក្រោម បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបានទេ បើផ្អែកលើទឡ្ហីករណ៍ណាមួយនៃទឡ្ហីករណ៍ទាំងនេះនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ។

*បណ្តឹងសាទុក្ខភ្លាមៗនៅក្រោមវិធាន ១០៤(៤)(ក) និងវិធាន ១០៥(២)*

8. ខៀវ សំផន តវ៉ាថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាននៅក្រោមវិធាន ១០៤(៤)(ក) ថាជាសេចក្តីសម្រេចមួយដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ដោយសារការប្រកាសនៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ បានឱ្យធ្វើឱ្យចប់សំណុំរឿង០០២/០២ ដោយពុំចាំបាច់មានសាលក្រមដែលអាចប្តឹងសាទុក្ខបាន[15]។

9. ផ្ទុយពីការលើកឡើងរបស់ ខៀវ សំផន គេច្បាស់ណាស់ថា ការប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មិនមាន "អានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" ទេ។ អ.ជ.ត.ក បានបញ្ជាក់អះអាងថា ខ្លួនមាន "យុត្តាធិការមានលក្ខណៈកំណត់សម្រាប់បណ្តឹងសាទុក្ខភ្លាមៗ នៅក្រោមវិធាន ១០៤(៤)"[16] និងបានកត់សម្គាល់ក្នុងឱកាសមួយចំនួនថា សនិទានភាពសម្រាប់វិធាន ១០៤(៤)(ក) គឺដើម្បីឱ្យ "ប្រាកដថា មានកន្លែងមួយសម្រាប់បណ្តឹងសាទុក្ខ ប្រសិនបើកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់*ដោយមិនទាន់ចេញសាលក្រម* ដូច្នេះទើបភាគីមិនមានឱកាសដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម"(សង្កត់ន័យដើមត្រង់ឃ្លាអក្សរទ្រេត)[17]។ ជាឧទាហរណ៍ ការរារាំង

[14] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ៩។

[15] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ២១-២៦។

[16] ឯកសារ **E51/6/1/1/2** សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ដោយ អៀង សារី, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១, ទំព័រ ២។

[17] ឯកសារ **E95/8/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២, កថាខណ្ឌ ៩។ ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹង

ទម្រាំមានសាលក្រមលើអង្គសេចក្តី បានក្លាយជាទឡ្ហីករណ៍មួយសម្រាប់បណ្តឹងសាទុក្ខភ្លាមៗ នៅពេលដែល តាមលទ្ធផលនៃសេចក្តីសម្រេចរបស់សាលាដំបូង កិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ ឬឮ្យរ ទាក់ទងនឹងទិដ្ឋភាពនៃចន្ទានុសិទ្ធិនៃការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ[18]។

10. សេចក្តីសម្រេចផ្នែកនីតិវិធីទាក់ទងនឹងពេលវេលានៃការប្រកាសសាលក្រម និងសាលក្រមជាលាយលក្ខណ៍អក្សរនៅពេលខាងមុខ មិនមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីទេ ពាក់ព័ន្ធនឹងការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ទោះជាមួយផ្នែក ឬទាំងស្រុងក៏ដោយ។ សសរស្តម្ភរបស់សាលក្រមត្រូវបានសម្រេច ហើយ ខៀវ សំផន ខ្លួនឯងបានយល់ស្របដែរ[19] គឺថាសាលក្រមគ្រាន់តែបានបញ្ចប់ដំណាក់កាលសវនាការប៉ុណ្ណោះ មិនមែនបញ្ចប់កិច្ចដំណើរការនីតិវិធីតុលាការសម្រាប់សំណុំរឿង០០២/០២ នោះទេ។

*ការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមតាមវិធាន ១០៥(១)(ខ)*

11. តាមវិធាន ១០៤(៤) ("សេចក្តីសម្រេចផ្សេងទៀត អាចប្តឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី")[20]។ តាមពិតនោះ អជតក បានបញ្ជាក់ថា ការជំទាស់ទៅនឹងសេចក្តីសម្រេចនានាអំពីលក្ខណៈនីតិវិធីដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលជំនុំជម្រះ ត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងពេលពេលប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តីស្របតាមវិធាន១០៤(១) និង

---

សាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ"), កថាខណ្ឌ ២២។ ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ"), កថាខណ្ឌ ២១។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ("សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពបន្ថែម"), កថាខណ្ឌ ១៧។

[18] **E301/9/1/1/3** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពបន្ថែម, កថាខណ្ឌ ១៨។

[19] **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ៤៨។

[20] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

១០៥(១)[21] នៃវិធានផ្ទៃក្នុង។ បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន បច្ចុប្បន្នប្រឆាំងនឹងជម្រើសនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងនេះ គឺមិនត្រឹមត្រូវតាមពេលវេលានោះទេ។ តាមហេតុផលដែលបង្ហាញជូនខាងក្រោម បណ្ដឹងសាទុក្ខប្រឆាំនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង អាចអនុញ្ញាតបានតែក្រោយពេលចេញសាលក្រមជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ហើយផ្ទុយទៅវិញ អំណះអំណាងរបស់ ខៀវ សំផន មិនមានអង្គសេចក្ដីទាល់តែសោះ[22]។

*យុត្តាធិការជាប់មកជាមួយ*

12. ជាចុងក្រោយ ផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន[23] នេះមិនមែនជាស្ថានភាពមួយដែល អជតក មាន "យុត្តាធិការជាប់មកជាមួយ" ដើម្បីធ្វើអន្តរាគមន៍នោះទេ។ អជតក និង អង្គបុរេជំនុំជម្រះ ("អបជ") ពីមុនមកបានរកឃើញថា ក្នុងករណីដែលបទប្បញ្ញត្តិលក្ខន្តិកៈមិនបានចែងច្បាស់លាស់ ឬតាមការសន្និដ្ឋានចាំបាច់អំពីអំណាចរបស់ខ្លួន ដើម្បីវិនិច្ឆ័យលើបញ្ហាណាមួយនោះ ពួកគេមានយុត្តាធិការជាប់មកជាមួយ "ដើម្បីសម្រេចលើបញ្ហាថែមទៀត *ដែលកើតចេញពីលទ្ធផលផ្ទាល់នៃកិច្ចដំណើរការនីតិវិធី ដែល [ពួកគេ] បានទទួល* ដោយផ្ដល់សម្អាងហេតុថា បញ្ហានោះស្ថិតនៅក្រោមយុត្តាធិការបឋម [របស់ខ្លួន]"[24]។ ដូច្នេះ យុត្តាធិការនេះជាយុត្តាធិការ "បន្ថែម ឬថែមទៀតក្រៅពីយុត្តាធិការបឋម ហើយត្រូវចាត់ទុកជាយុត្តាធិការចាំបាច់ [នៅពេល] មានតម្រូវការចាំបាច់ដើម្បីធានាថា កិច្ចការរដ្ឋបាលតុលាការដំណើរការបានល្អ និងត្រឹមត្រូវ យុត្តិធម៌"[25]។ ឧទាហរណ៍ ជារឿយៗវាត្រូវបានគេប្រើដើម្បីដាក់ចេញនូវវិធានការបណ្ដោះអាសន្ន[26]។

---

[21] ឯកសារ **F36** សំណុំរឿង០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សំណុំរឿង០០២/០១ សាលដីកា") កថាខណ្ឌ ៩៦។

[22] *សូមមើល យោងខាងក្រោម* កថាខណ្ឌ ២២ និងជើងទំព័រ ៥៩។

[23] ឯកសារ **E463/1** បណ្ដឹងសាទុក្ខ កថាខណ្ឌ ២៨។

[24] **<u>អជតក៖</u>** ឯកសារ **E284/2/1/2** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំការបំភ្លឺ") កថាខណ្ឌ ១២។ **<u>អបជ៖</u>** សំណុំរឿង០០៣-**D14/1/2** ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្ដីពីសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង០០៣" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ("ដីកាសម្រេចព្យួររបស់ អបជ") កថាខណ្ឌ៤។

[25] ឯកសារ **E284/2/1/2** សេចក្ដីសម្រេចរបស់ អជតក លើសំណើសុំការបំភ្លឺ កថាខណ្ឌ ១២។ សំណុំរឿង០០៣-**D14/1/2** ដីកាសម្រេចព្យួររបស់ អ.ប.ជ កថាខណ្ឌ៤។

[26] ឯកសារ **E284/2/1/2** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំការបំភ្លឺ កថាខណ្ឌ ១២ និងយោងសម្អាងខាងក្នុងនោះ។

13. ហេតុដូច្នេះ ចំពោះបណ្ដឹងសាទុក្ខបច្ចុប្បន្ននេះ ដើម្បីឲ្យស្ថិតនៅក្នុងវង្វង់សមត្ថកិច្ចនៃយុត្តាធិការជាប់មកជាមួយរបស់ អជតក នោះ ខៀវ សំផន ត្រូវតែបង្ហាញឲ្យឃើញថា ការខកខានមិនបានមោឃភាពសាលក្រម និងការកាត់សេចក្ដី ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឬការអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសម្អាងហេតុជាលាយលក្ខណ៍អក្សររបស់ខ្លួន ក្នុងពេលឆាប់ៗនេះ អាចមានផលប៉ះពាល់ផ្ទាល់លើកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ដែលត្រូវបានប្ដឹងទៅកាន់ អជតក រួចហើយនោះ ឧទាហរណ៍ ដោយការផ្ដល់ជូនសិទ្ធិឲ្យប្ដឹងសាទុក្ខមិនមានប្រសិទ្ធភាព ឬប៉ះពាល់ដល់ភាពត្រឹមត្រូវនៃដំណើរការបណ្ដឹងសាទុក្ខដែលមានស្រាប់[27]។ ដោយសារតែបច្ចុប្បន្ននេះមិនមានកិច្ចដំណើរការនីតិវិធីផ្ទាល់នៅចំពោះមុខ អជតក ស្ថានភាពបែបនេះមិនកើតមានឡើងនៅទីនេះទេ។

## ខ. អង្គសេចក្ដី

14. បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ផ្អែកលើទស្សនៈដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសនីតិវិធី ដោយការប្រកាសសាលក្រមសំណុំរឿង ០០២/០២ ដោយភ្ជាប់ជាមួយដោយសាលក្រមសង្ខេប និងផ្នែកសម្រេចសេចក្ដី នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ប៉ុន្តែខកខានមិនបានបោះពុម្ពផ្សាយសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរនៅថ្ងៃជាមួយគ្នានោះ។ រូបគាត់បានអះអាងថា នេះគឺជាការរំលោភបំពានលើមាត្រា ១០១ និង ១០២ នៃវិធានផ្ទៃក្នុង និងជាការអនុវត្តដែលមិនអាចអនុញ្ញាឲ្យធ្វើទៅបានចំពោះការបោះពុម្ពផ្សាយសាលក្រមអង្គជំនុំជម្រះសាលាដំបូងនេះ[28]។ ជាងនេះទៀត រូបគាត់អះអាងថា ដោយសារមិនមានសាលក្រមជាលាយលក្ខណ៍អក្សរត្រូវបានចេញនៅថ្ងៃនោះ សេចក្ដីសង្ខេប និងផ្នែកសម្រេចសេចក្ដីបង្កើតបានជា "សាលក្រម" ទាំងមូលក្នុងន័យនៃវិធាន៩៨ និង ១០១ នៃវិធានផ្ទៃក្នុង[29] ដែល (i) ត្រូវមោឃៈចំពោះកំហុសនីតិវិធី និងកង្វះខាតសម្អាងហេតុ[30] (ii) បណ្ដាលឲ្យមានការភាន់ច្រឡំអំពីទម្រង់ និងពេលវេលាកំណត់សម្រាប់ការប្ដឹងសាទុក្ខ[31] និង (iii) ធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូង*ចប់ភារកិច្ច* ដែលអង្គជំនុំជម្រះ

[27] ឯលសារ **E284/2/1/2** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំការបំភ្លឺ កថាខណ្ឌ ១២។ សំណុំរឿង០០៣-**D14/1/2** ដីកាសម្រេចឭររបស់ អ.ប.ជ កថាខណ្ឌ ៣-៥។

[28] ឯកសារ **E463/1** បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣-៤, ៥-៧, ៣៩-៤៧។

[29] ឯកសារ **E463/1** បណ្ដឹងសាទុក្ខ កថាខណ្ឌ ១០-១១, ៣៧។

[30] ឯកសារ **E463/1** បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣-៥, ៥៤-៦៤, ៧០, ៧៣។

[31] ឯកសារ **E463/1** បណ្ដឹងសាទុក្ខ កថាខណ្ឌ ៤, ៨-២៧, ៣៤-៣៥។

នេះលែងមានយុត្តាធិការបែបនេះ ដើម្បីបោះពុម្ពផ្សាយសាលក្រមជាលាយលក្ខណ៍អក្សរទៀតហើយ[32]។ ជាលទ្ធផល ខៀវ សំផន អះអាងថាខ្លួនត្រូវបានដកហូតសិទ្ធិនីតិវិធីជាច្រើន រួមទាំងសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងខ្លឹមសារនៃសាលក្រមប្រឆាំងនឹងរូបគាត់ សិទ្ធិក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព សិទ្ធិទទួលបានភាពប្រាកដប្រជាផ្នែកច្បាប់ និងសិទ្ធិទទួលបានការស្តាប់សវនាការក្នុងរឿងក្តីគាត់ ហើយហេតុដូច្នេះរូបគាត់បានទទួលរងព្យសនកម្មធ្ងន់ធ្ងរ[33]។

*អង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តកំហុសអង្គច្បាប់ណាមួយឡើយ*

15. អំណះអំណាងរបស់ ខៀវ សំផន មិនត្រឹមត្រូវដោយមូលហេតុជាច្រើន។ ទីមួយ ន័យត្រង់ និងគោលបំណងរបស់វិធាន ១០១ និង ១០២ នៃវិធានផ្ទៃក្នុង នៅពេលអានរួមគ្នា គឺត្រូវដាក់ចេញទម្រង់ដែលត្រូវការ និងខ្លឹមសារនៃសាលក្រមជាលាយលក្ខណ៍អក្សរ[34] និងត្រូវផ្តល់នូវការអនុញ្ញាតឲ្យមានការប្រកាសជាសាធារណៈ[35] រួមទាំងការប្រកាសផ្ទាល់មាត់នូវសាលក្រមសង្ខេបនៃការរកឃើញ និងផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូង[36]។ ធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងការពាររាល់សិទ្ធិជាមូលដ្ឋានទាំងអស់របស់ជនជាប់ចោទ រួមទាំងសិទ្ធិទទួលបានសវនាការជាសាធារណៈ សាលក្រមសម្អាងហេតុ និងសិទ្ធិប្តឹងសាទុក្ខ ក៏ដូចជា ការធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងសាធារណជនទទួលបានព័ត៌មានអំពីដំណើរការតុលាការ។ មិនមានត្រង់ណាក្នុងវិធានទាំងនេះ ឬកន្លែងណាផ្សេងទៀត ហាមឃាត់អង្គជំនុំជម្រះសាលាដំបូងពីការបំពេញ*ភារកិច្ចក្នុងការប្រកាសសាលក្រមជាសាធារណៈ*មុនពេលការបោះពុម្ពផ្សាយសម្អាងហេតុជាលាយលក្ខណ៍អក្សរនោះឡើយ ហើយវិធានក៏មិនបានចែងថា ការធ្វើដូច្នេះធ្វើឲ្យសាលក្រមនេះអសុពលភាពនោះដែរ។

16. ដូចដែល ខៀវ សំផន រៀបរាប់ម្តងមួយៗយ៉ាងលម្អិតនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន[37] អជតក[38] អបជ[39] និងអង្គជំនុំជម្រះសាលាដំបូង[40] ទាំងអស់គ្នាបានធ្វើតាមការអនុវត្តនេះនៅពេលបោះពុម្ព

[32] ឯកសារ **E463/1** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៦-៥៤, ៧៣។

[33] ឯកសារ **E463/1** បណ្តឹងសាទុក្ខ កថាខណ្ឌ ៤, ២៦, ៣៣-៣៤, ៦០-៦៩។

[34] វិធាន ១០១ នៃវិធានផ្ទៃក្នុង។

[35] វិធាន ១០២ នៃវិធានផ្ទៃក្នុង។

[36] វិធាន ១០២(១) នៃវិធានផ្ទៃក្នុង។

[37] ឯកសារ **E463/1** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៩-៤៧។

ផ្សាយសាលក្រម និងសេចក្ដីសម្រេចរបស់ពួកគេ។ អជតក បានបញ្ជាក់រួចហើយថា ការពន្យារពេលណាមួយរវាងការចេញសេចក្ដីសង្ខេប និងផ្នែកសម្រេចសេចក្ដី វាគឺជារឿងមួយ ហើយសម្អាងហេតុជាលាយលក្ខណ៍អក្សរ គឺជារឿងមួយផ្សេងទៀត មិនបង្កើតបានជាការរំលោភបំពាននីតិវិធីនោះទេ[41]។ ជាងនេះទៀត មាត្រា ៣៣*ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អវតក[42] អនុញ្ញាតយ៉ាងច្បាស់ឱ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកការណែនាំពីវិធាន និងបទដ្ឋាននីតិវិធីអន្តរជាតិ ប្រសិនបើ នីតិវិធីដែលមានស្រាប់ មិនដោះស្រាយបញ្ហាជាក់លាក់ណាមួយនោះ ឬ ប្រសិនបើមានចម្ងល់អំពីភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។ វិធានស្ដីពីភស្តុតាង និងនីតិវិធី (“RPE”)

---

[38] *សូមមើ ឧទាហរណ៍* ឯកសារ **E284/4/7** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ សេចក្ដីសង្ខេបនៃសម្អាងហេតុ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ដាក់តាមក្រោយដោយឯកសារ **E284/4/8** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២។ *សូមមើលបន្ថែមទៀត* ឯកសារ **E463/1** បណ្ដឹងសាទុក្ខ ជើងទំព័រ ១៨-១៩។

[39] *សូមមើល ឧទាហរណ៍* ឯកសារ **D427/1/26** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដាក់តាមក្រោយដោយឯកសារ **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។ *សូមមើលបន្ថែមទៀត* ឯកសារ **E463/1** បណ្ដឹងសាទុក្ខ ជើងទំព័រ ២០-២២។

[40] *សូមមើល ឧទាហរណ៍* ឯកសារ **E367/7** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងសក្ខីកម្មរបស់ 2-TCE-95 ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ ដាក់តាមក្រោយដោយឯកសារ **E367/8** ដីកាសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន (៤) សុំឱ្យទទួលយកឯកសារចំនួន ២៩ ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95 ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦។ *សូមមើលបន្ថែមទៀត* ឯកសារ **E463/1** បណ្ដឹងសាទុក្ខ ជើងទំព័រ២៤។

[41] **E50/1/1/4** សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣១, ៣៨ [“ប្រសិនបើ [...] ផ្នែកសម្រេចសេចក្ដី និងសម្អាងហេតុ ត្រូវចេញក្នុងរយៈពេលកំណត់បញ្ហានៃការបំបែកនេះ ពុំមែនជាបញ្ហាចោទឡើយ។” អ.ជ.ត.ក បានរកឃើញថា មុនពេលផុតកំណត់រយៈពេលកំណត់បួនខែដែលមានចែងក្នុងវិធាន ៦៨(២) នៃវិធានផ្ទៃក្នុង អ.ប.ជ បានដាក់ដីកាសម្រេចមានសម្អាងហេតុពេញលេញរបស់ខ្លួន ហើយហេតុដូច្នេះគោរពតាមកាតព្វកិច្ចនីតិវិធីក្នុងវិធានផ្ទៃក្នុង]។ *សូមមើលផងដែរ* ឯកសារ **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ២២។

[42] ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ *ដូចដែលត្រូវបានវិសោធនកម្ម* នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

នៅតុលាការ ICTY, ICTR, MICT និង STL អនុញ្ញាតយ៉ាងច្បាស់លាស់សម្រាប់នីតិវិធីនេះ[43] ហើយអង្គជំនុំជម្រះនៅតុលាការ ICTY, ICTR និង SCSL ទាំងអស់គ្នាបានប្រកាសសាលក្រម ដោយមានសាលក្រមសង្ខេប មុនពេលសាលក្រមជាលាយលក្ខណ៍អក្សរត្រូវបានបោះពុម្ពផ្សាយ[44]។ វាច្បាស់ណាស់ថា នីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ស្របគ្នាជាមួយនឹងបទដ្ឋាន

[43] វិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការ ICTY វិធាន ៩៨*ស្ទួនមួយ*(ក), (គ)។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការ ICTR វិធាន ៩៨(ក), (គ) ["(ក) សាលក្រមត្រូវប្រកាសជាសាធារណៈ តាមកាលបរិច្ឆេទដែលបានជូនដំណឹងដល់ភាគី និងស្នាក្តី ហើយដែលពួកគេត្រូវមានវត្តមាន [...] (គ) វាត្រូវអមមកជាមួយ ឬដាក់តាមក្រោយយ៉ាងឆាប់បំផុតដែលធ្វើបាន ដោយយោបល់សម្អាងហេតុជាលាយលក្ខណ៍អក្សរ"]។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការ MICT វិធាន១២២(ក), (គ) ["(ក) សាលក្រមត្រូវប្រកាសជាសាធារណៈដោយអង្គជំនុំជម្រះសាលាដំបូង [...] នៅកាលបរិច្ឆេទដែលបានជូនដំណឹងដល់ភាគី និងស្នាក្តី និងដែលពួកគេត្រូវមានវត្តមាន [...] (គ) [...] វាត្រូវអមមកជាមួយ ឬដាក់តាមក្រោយយ៉ាងឆាប់បំផុតដែលធ្វើបាន ដោយយោបល់សម្អាងហេតុជាលាយលក្ខណ៍អក្សរ"]។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៃតុលាការ STL វិធាន ១៦៨(ក)-(ខ) ["(ក) សាលក្រមត្រូវប្រកាសជាសាធារណៈ តាមកាលបរិច្ឆេទដែលបានជូនដំណឹងដល់ភាគី ហើយជនរងគ្រោះដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងដែលពួកគេត្រូវមានវត្តមាន [...] (ខ) [...] វាត្រូវអមមកជាមួយ ឬដាក់តាមក្រោយយ៉ាងឆាប់បំផុតដែលធ្វើបានដោយយោបល់សម្អាងហេតុជាលាយលក្ខណ៍អក្សរ"]។

[44] *សូមមើល ឧទាហរណ៍* **ICTR**: (១) *Ngirabatware*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ដែលបានដាក់ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ (*សូមមើល Ngirabatware*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១)។ (២) *Ndindiliyimana និងគូកន*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១១ ដែលបានដាក់ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ (*សូមមើល Ndindiliyimana និងគូកន*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ កថាខណ្ឌ ១)។ (៣) *Ndahimana*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ចុះហត្ថលេខាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ និងបានដាក់ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ (*សូមមើល Ndahimana*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ ជើងទំព័រ១)។ (៤) *Nzabonimana*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ បានដាក់នៅថ្ងៃទី ២៥ មិថុនា ឆ្នាំ២០១២ (*សូមមើល Nzabonimana*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ជើងទំព័រ១)។ (៥) *Nyiramasuhuko និងគូកន*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ចេញជាលាយលក្ខណ៍អក្សរជាភាសាអង់គ្លេស នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ (*សូមមើល Nyiramasuhuko និងគូកន* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ១)។ (៦) *Hategekimana*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ បានដាក់ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ (*សូមមើល Hategekimana*, អង្គជំនុំជម្រះសាលាអង្គជំនុំជម្រះសាលាដំបូង សាលក្រម និងការកាត់សេចក្តី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ បានដាក់ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៥ (*សូមមើល Muhimana*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក កថាខណ្ឌ ២ (ទំព័រ ៩២))។ **ICTY**: (១) *Aleksovski* អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ ដោយមានសេចក្តីសង្ខេបអាននៅថ្ងៃទី៧

អន្តរជាតិរបស់តុលាការនានាដែលដោះស្រាយរឿងក្ដីដែលមានទំហំ និងភាពធ្ងន់ធ្ងរស្រដៀងគ្នា នេះ។

17. អំណះអំណាងរបស់ ខៀវ សំផន ដែលនៅសល់ទាំងអស់ចេញពីការអះអាងរបស់គាត់ថា នៅក្នុងពេលអវត្តមានសាលក្រមជាលាយលក្ខអក្សរដែលបានចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នោះ សេចក្ដីសង្ខេបដោយផ្ទាល់មាត់ និងផ្នែកសម្រេចសេចក្ដីចាំបាច់ បង្កើតបានជា "សាលក្រមនៅក្នុងសំណុំរឿង០០២/០២"។ ការណ៍នេះគឺមិនពិត និងបង្ហាញដោយខុសឆ្គងដោយចេតនា និងស្ថានភាពនៃការប្រកាសសាលក្រមនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូង បានថែងនៅក្នុងដីកាកំណត់កាលបិច្ឆេទប្រកាសសាលក្រមរបស់ខ្លួន[45] និងដីកាកោះជនជាប់ចោទ[46] សវនាការសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នោះ ត្រូវបានធ្វើឡើងជាការបំពេញកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង តាមវិធាន១០២(១) ដើម្បីប្រកាសសាលក្រមជាសាធារណៈ ដោយបានផ្ដល់នូវ "សេចក្ដីសង្ខេបនៃការកឃើញ និងផ្នែកសម្រេចសេចក្ដី"[47] ដោយមានសេចក្ដីសម្រេចសាលក្រម និងការកាត់ទោសដែលជាប់កាតព្វកិច្ច។ អង្គជំនុំជម្រះសាលាដំបូងថែមទាំងបានច្បាស់លាស់ដូចគ្នាដែរថា សំណៅសម្អាងហេតុជាលាយលក្ខណ៍អក្សរនឹងចេញ

---

ខែឧសភា ឆ្នាំ១៩៩៩ (*សូមមើល* *Aleksovski*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ២)។ (២) *Rašić*, អង្គជំនុំជម្រះសាលាដំបូង សម្អាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សាលក្រមកាត់សេចក្ដី ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ១ ("នៅក្នុងនេះ អង្គជំនុំជម្រះសាលាដំបូងដាក់ចេញនូវសម្អាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់ការកាត់សេចក្ដីផ្ទាល់មាត់ ដែលបានចេញនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១២")។ **SCSL**: *Taylor*, អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ ដោយមានសេចក្ដីសង្ខេបផ្ទាល់មាត់អាននៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ (*សូមមើល* *Taylor* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា កថាខណ្ឌ១២)។

[45] ឯកសារ **E462** ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២, ទំព័រទី២ ["**ជូនដំណឹង** ដល់ភាគីនានាថា អនុលោមតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងប្រកាសសេចក្ដីសង្ខេបសម្អាងហេតុ និងផ្នែកសម្រេចសេចក្ដីនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក"]។

[46] ឯកសារ **E202/340** ដីកាកោះជនជាប់ចោទ, ទំព័រ១ [កោះហៅឈ្មោះ៖ នួន ជា និង ខៀវ សំផន ឲ្យចូលមកកាន់បន្ទប់សាលសវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ "ដើម្បីចូលរួមសវនាការប្រកាសសាលក្រមនៃសំណុំរឿង ០០២/០២"]។

[47] វិធាន១០២(១) នៃវិធានផ្ទៃក្នុង ["គ្រប់សាលក្រមទាំងអស់ត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកសង្ខេបនៃសម្អាងហេតុ និងផ្នែកសម្រេចសេចក្ដី ត្រូវតែអានខ្លាំងៗដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ឬសមាជិកនៃអង្គជំនុំជម្រះណាម្នាក់"]។

តាមក្រោយជាបន្តទៀត[48] ដូច្នេះហើយ វានឹងបំពេញលក្ខខណ្ឌតម្រូវនីតិវិធីសម្រាប់សាលក្រមមួយជាលាយលក្ខណ៍អក្សរ ដោយយោងតាមវិធាន១០១។

18. ការពឹងផ្អែករបស់ ខៀវ សំផន ទៅលើការពិចារណារបស់ អ.ប.ជ លើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិទល់នឹងដីកាដំណោះស្រាយ (សម្អាងហេតុ) នៅក្នុងសំណុំរឿង០០៤/១[49] - ដែលនៅក្នុងនោះ អ.ប.ជ បានរកឃើញថា "ការចេញសម្អាងហេតុនៅពេលក្រោយមកទៀត ... មិនអាចអនុវត្តចំពោះដីកាដំណោះស្រាយបានទេ"[50] ដូច្នោះ គឺមិនសមហេតុសមផលនោះទេ។ បញ្ហានៅទីនោះ ទាក់ទងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (ស.ច.ស) ទៅនឹងបញ្ហាដំបូងគេនៃដីកាដំណោះស្រាយជាលាយលក្ខណ៍អក្សរ តែកង្វះសម្អាងហេតុ ដែលដោយសារតែមិនមានសម្អាងហេតុនេះហើយ វាមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវជាក់លាក់នៃវិធានផ្ទៃក្នុង ៦៧(៤)[51]។ ដូចបាននិយាយរួចហើយ នៅក្នុងសំណុំរឿង០០២/០២ អង្គជំនុំជម្រះសាលាដំបូងគឺគ្រាន់តែបំពេញតាមចំណុចពេលវេលាចំនួនពីរដាច់ដោយឡែកគឺ លក្ខខណ្ឌតម្រូវ *ដាច់ខាត* សម្រាប់ការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមួយ។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ខៀវ សំផន បានថ្លែង ដោយខុសឆ្គងពីសេចក្តីសម្រេចរបស់ អ.ប.ជ ដោយអះអាងថា អ.ប.ជ បានខុសឆ្គង ខកខានមិនបានទាញពីផលវិបាកនានាដែលចេញមកពីការបំពានលើនីតិវិធី[52]។ តាមការពិត សេចក្តីសម្រេចរបស់ អ.ប.ជ គឺមានលក្ខណៈយ៉ាងច្បាស់លាស់ណាស់៖ ខណៈដែលដីកាសម្រេច (សង្ខេប) លើកទីមួយ មិនត្រូវតាមលក្ខខណ្ឌតម្រូវនីតិវិធីនៃវិធានផ្ទៃក្នុង ៦៧(៤)

[48] ឯកសារ **E462** ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២, ទំព័រទី២ ["**ជូនដំណឹង** ដល់ភាគីនានាថា អង្គជំនុំជម្រះនឹងជូនដំណឹងអំពីសម្អាងហេតុពេញលេញនៃសាលក្រមនេះ នៅក្នុងពេលវេលាមួយសមស្រប"]។ ឯកសារ **E1/529.1** សេចក្តីប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២, ប្រតិចារឹក, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ម៉ោង៖ 09.34.35-09.36.02 ["សម្អាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់ គឺជាសម្អាងហេតុដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរនៅក្នុងសាលក្រម ដែលមានជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ដែលអង្គជំនុំជម្រះនឹងចេញនៅក្នុងពេលសមស្របខាងមុខ"]។

[49] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ៤៤-៤៦។

[50] សំណុំរឿង ០០៤/០១ - ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ), ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹងដីកាដំណោះស្រាយ"), កថាខណ្ឌ ៣៣។

[51] សំណុំរឿង ០០៤/០១ - ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៣។

[52] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ៤៦។

នោះសេចក្តីសម្រេចរបស់ ស.ច.ស បានចេញថា វាមិនបានធ្វើឱ្យដីកាដំណោះស្រាយទីពីរដែលមានសម្អាងហេតុនោះទៅជាមោឃៈនោះទេ។ តាមការពិត អ.ប.ជ បានសម្រេចថា "ទោះបីក្នុងកាលៈទេសៈមួយចំនួន ការចេញសម្អាងហេតុនៅពេលក្រោយមកទៀត អាចបំពេញទៅតាមកាតព្វកិច្ចក្នុងការចេញដីកាសម្រេចដែលមានសម្អាងហេតុ"[53]។

*ខៀវ សំផន មិនទទួលរងនូវព្យសនកម្មណាឡើយ*

19. វាជាការគួរឱ្យកត់សម្គាល់ថា មិនមានកន្លែងណានៅក្នុងបណ្តឹងសាទុក្ខរបស់គាត់ដែល ខៀវ សំផន បានបង្ហាញថា ការប្រកាសដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបសាលក្រមនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ជាបីភាសា មុននឹងមានសាលក្រមជាលាយលក្ខណ៍អក្សរពេញលេញត្រូវបានចេញជាលើកដំបូងជាពីរភាសា ធ្វើឱ្យខូចខាតណាមួយដល់រូបគាត់ឡើយ។ មិនមានមោឃកម្មណាមួយនៃសេចក្តីសម្រេចសាលក្រម និងការដាក់ទោស ត្រូវសមនឹងបានទទួលនោះទេ នៅពេលដែលមិនមានកំហុសណាមួយត្រូវបានទទួលនូវការខូចខាត។ ពីមុនមក អ.ជ.ត.ក ធ្លាប់បានសម្រេចថា មានតែកំហុសនីតិវិធីប៉ុណ្ណោះ ដែលនឹងនាំឱ្យមានការកែប្រែនូវសាលក្រម គឺកំហុសដែលបណ្តាលឱ្យ "មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ" ដោយគិតពីគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ដោយរួមទាំង វិធានការដែលត្រូវចាប់យកនៅក្នុងដំណាក់កាលនៃបណ្តឹងសាទុក្ខនេះផង[54]។ អ.ជ.ត.ក បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងជាញឹកញាប់បានរីករាយនឹងឆន្ទានុសិទ្ធិទាក់ទងនឹងបញ្ហានីតិវិធីនានា[55] និងបានកំណត់យកនូវវិធីសាស្ត្រមួយដែលបង្ហាញនូវសេចក្តីគោរព ដើម្បីពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិនេះ ដោយធ្វើអន្តរាគមន៍នៅក្នុងការប្រតិបត្តិឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង

---

[53] សំណុំរឿង ០០៤/០១ - ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៣។

[54] ឯកសារ **F36** សំណុំរឿង ០០២/០១ សាលដីកា, កថាខណ្ឌ ១០០។

[55] ឯកសារ **F36** សំណុំរឿង ០០២/០១ សាលដីកា, កថាខណ្ឌ ៩៧, *លើកឡើងពី* ឯកសារ **E189/3/1/8** សេចក្តីសម្រេច លើ "បណ្តឹងសាទុក្ខភ្លាមរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់តាមវិធាន ៣៥", ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣, កថាខណ្ឌ២១, ២៦។ ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ, កថាខណ្ឌ៣០។ ឯកសារ **E116/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង ភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ៣៣។

តែកាលណាបើសិនជាវាត្រូវបានប្រឡាក់ប្រឡូសទៅដោយកំហុសដែលអាចយល់ដឹងបាន ដែលបណ្តាលឲ្យមានព្យសនកម្មទៅខាងដើមបណ្តឹងសាទុក្ខប៉ុណ្ណោះ[56]។

20. ខៀវ សំផន មិនបានបង្ហាញពីការរំលោភទៅលើសិទ្ធិរបស់គាត់*ណាមួយឡើយ* តាមរយៈកំហុសដែលគាត់បានលើកឡើង។ តាមការពិត បើកង្វល់របស់គាត់ជាការពិតមែននោះ គាត់ត្រូវតែធ្វើវាឡើងឲ្យបានឆាប់ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមរបស់ខ្លួន កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ជាជាងរង់ចាំរហូតដល់ក្រោយថ្ងៃប្រកាសសាលក្រមនៅ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

21. ខៀវ សំផន បានលើកឡើងថា គាត់បានស្ថិតនៅក្រោមភាពអាម៉ាស់ជាសាធារណៈដោយសារការកាត់ឲ្យជាប់ទោសរបស់គាត់នៅចំពោះមុខអ្នកស្តាប់ជាតិ និងអន្តរជាតិ ដោយមិនមានលទ្ធភាពប្តឹងសាទុក្ខលើការកាត់ឲ្យជាប់ទោសរបស់គាត់លើអង្គសេចក្តីនោះបាន[57]។ យ៉ាងណាក៏ដោយ ដូចបានថែងនៅខាងលើស្រាប់ហើយថាការប្រកាសជាសាធារណៈនូវសាលក្រមអង្គជំនុំជម្រះសាលាដំបូងមិនមែនគ្រាន់តែត្រូវបានដាក់ជាអាណត្តិដោយវិធាននៃផ្ទៃក្នុងរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជាទិដ្ឋភាពខាងក្នុងមួយនៃសវនាការព្រហ្មទណ្ឌមួយ ដែលធានាបាននូវតម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងការចូលរួមរបស់សាធារណជននៅក្នុងនីតិវិធីរបស់តុលាការ។ ព្រឹត្តិការណ៍សំខាន់នេះនឹងមានកើតឡើង មិនថាមាន ឬមិនមានសាលក្រមជាលាយលក្ខណ៍អក្សរត្រូវបានចេញនៅថ្ងៃតែមួយដូចគ្នានោះទេ។

22. ស្រដៀងគ្នានេះដែរ ខៀវ សំផន មិនត្រូវបានដកហូតនូវសិទ្ធិរបស់គាត់ទៅនឹងសាលក្រមជាលាយលក្ខណ៍អក្សរ ឬបណ្តឹងសាទុក្ខនោះទេ ហើយមិនអើពើនឹងអង្គហេតុដែលថាអង្គជំនុំជម្រះសាលាដំបូងបានថ្លែងយ៉ាងច្បាស់លាស់ និងដោយសាធារណៈដោយយោងតាមវិធាន ១០១(៦)(i)[58] ១០៧(៤)[59] និង ៣៩(១) និង (៤)[60] ថាពេលវេលាសម្រាប់ដាក់បណ្តឹងសាទុក្ខណាក៏ដោយ នឹងត្រូវ

---

[56] ឯកសារ **F36** សំណុំរឿង ០០២/០១ សាលដីកា, កថាខណ្ឌ ៩៧។

[57] ឯកសារ **E463/1** បណ្តឹងសាទុក្ខ, កថាខណ្ឌ ៦៦-៦៨។

[58] វិធាន ១០១(៦)(i) នៃវិធានផ្ទៃក្នុង [សាលក្រមត្រូវតែមានរួមបញ្ចូលនូវសេចក្តីថ្លែងអពី "សិទ្ធិប្តឹងសាទុក្ខរបស់ភាគី និងលក្ខខណ្ឌ និងពេលវេលាកំណត់សម្រាប់ប្តឹងសាទុក្ខ"]។

[59] វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង ["សេចក្តីសុំប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដូចមានកំណត់នៅក្នុងវិធាន ១០៥(៣) ត្រូវធ្វើក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាសលក្រម ឬការជូនដំណឹងពីសាលក្រមនោះ តាមករណីសមស្រប"]។ *សូមអានបន្ថែមទៀត* វិធាន ១០៨(១) នៃវិធានផ្ទៃក្នុង ["ក្នុងករណីមានបណ្តឹងសាទុក្ខចំពោះសាលក្រម

ចាប់ផ្តើមក្រោយពេលដែលសេចក្តីសម្រេចមានសម្អាងហេតុយ៉ាងពេញលេញ ត្រូវបានជូនដំណឹងជាពីរភាសា[61]។ ដោយមិនស្របគ្នា តាមរយៈបណ្តឹងសាទុក្ខនេះ ខៀវ សំផន បានស្វែងរកធ្វើមោឃភាព ឬពន្យារពេលគ្រប់ឯកសារទាំងអស់-គឺសាលក្រមមានសម្អាងហេតុយ៉ាងពេញលេញ - ដែលសូម្បីតែនៅក្នុងអំណះអំណាងរបស់គាត់ផ្ទាល់ ក៏ត្រូវតែដោះស្រាយនូវកំហុសឆ្គងដែលគាត់បានលើកឡើងនោះដែរ។ តាមពិតទៅ តាមរយៈការផ្តល់នូវសេចក្តីសង្ខេបសាលក្រមមួយ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ដល់ ខៀវ សំផន នូវពេលវេលាកាន់តែ*ច្រើនថែមទៀត* ដើម្បីចាប់ផ្តើមត្រៀមរៀបចំដំណាក់កាលបណ្តឹងសាទុក្ខនៃកិច្ចដំណើរការនីតិវិធី។ បើ ខៀវ សំផន មានបំណងចង់ ឬមួយស្វែងរកការបញ្ជាក់ ឬមួយពន្យារកាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខ គឺគាត់អាចគ្រាន់តែដាក់ជូនទៅ អ.ជ.ត.ក ឱ្យធ្វើដូច្នោះបាន ដោយអនុលោមតាមវិធាន ៣៩(៤) គឺដូចគ្នាទៅនឹងអ្វីដែលគាត់បានធ្វើនៅក្នុងសំណុំរឿង០០២/០១ ដែរ[62]។

## IV. សេចក្តីសន្និដ្ឋាន

23. ចំពោះហេតុផលទាំងឡាយដូចបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលទាំងស្រុងនូវបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

របស់អង្គជំនុំជម្រះសាលាដំបូង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ដោយភ្ជាប់ជាមួយនូវឯកសារថតចម្លងនៃសាលក្រម និងសេចក្តីជូនដំណឹងនីមួយៗនៃបណ្តឹងសាទុក្ខនេះ ដែលមានបញ្ជាក់ថា បានថតចម្លងត្រឹមត្រូវ"]។

[60] វិធាន៣៩(១) និង(៤) នៃវិធានផ្ទៃក្នុងចែងថាអង្គជំនុំជម្រះអាចកំណត់ និងអាចពន្យារពេលវេលាកំណត់ដែលខ្លួនបានកំណត់ក្នុងញត្តិរបស់ខ្លួន។

[61] ឯកសារ **E1/529.1** សេចក្តីប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២, ប្រតិចារឹក, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ម៉ោង៖ 11.37.57-11.40.00។

[62] ឯកសារ **F3** សំណើបន្ទាន់របស់មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្តឹងសាទុក្ខ, ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ៥, ៣១។